# ប្រទេសកម្ពុជា

| តារាងលេខ ១ | 2016 |
|---|---|
| ចំនួនប្រជាជន គិតជាលាននាក់ | 15.8 |
| ផសស គិតជា ប៊ីលានដុល្លារអាមេរិកក្នុងពេលបច្ចុប្បន្ន | 20.0 |
| ផសស ក្នុងពលរដ្ឋម្នាក់ៗ គិតជាដុល្លាអាមេរិកក្នុងពេលបច្ចុប្បន្ន | 1265 |
| អត្រាភាពក្រីក្រ (១.៩ ដុល្លារ/មួយថ្ងៃគិតតាម PPP ឆ្នាំ២០១១)[a] | 1.7 |
| អត្រាភាពក្រីក្រ (៣.១ ដុល្លារ/មួយថ្ងៃគិតតាម PPP ឆ្នាំ២០១១)[a] | 19.5 |
| សន្ទស្សន៍ជីនី[b] | 28.0 |
| អត្រាចុះឈ្មោះចូលរៀនបឋមសិក្សា (% ដុល)[b] | 123.0 |
| ជីវិតសង្ឃឹមរស់ពេលកើត គិតជាឆ្នាំ[b] | 67.8 |

ប្រភព: World Bank WDI and Macro Poverty Outlook.

សម្គាល់:

(a) តួលេខថ្មីបំផុត (២០១២)

(b) តួលេខថ្មីបំផុត របស់ WDI (២០១៤)


## *សេចក្តីសង្ខេប*

*កំណើនសេដ្ឋកិច្ចបានថមថយល្បឿនបន្តិចមកត្រឹម ៦.៩ ភាគរយនៅឆ្នាំ ២០១៦ (រូបលេខ ១) ហើយអត្រាកំណើនត្រូវបានព្យាករណ៍ថា ជាទូទៅ នឹងនៅតែមិនប្រែប្រួលរហូតដល់ឆ្នាំ ២០១៨ ។ ការថយចុះនូវការនាំចេញសម្លៀកបំពាក់ ត្រូវបានប៉ះប៉ូវមកវិញដោយការកើនឡើងនៃផលិតកម្មកសិកម្ម ទោះបីជាតម្លៃកសិផលនៅតែមានតម្លៃថោកនៅឡើយ ។ ពិពិធកម្មគ្រួសារជនបទដែលមានប្រភពប្រាក់ចំណូលមិនមែនកសិកម្ម ដូចជា (កាត់ដេរ សេវាកម្ម ការផ្ញើប្រាក់មកផ្ទះ) អាចជាកត្តារួមចំណែកសំខាន់ចំពោះការកាត់បន្ថយភាពក្រីក្រ និងវិបុលភាពទូទៅនៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ ហានិភ័យរួមមានផលអវិជ្ជមានពីការកើនឡើងនៃអត្រាការប្រាក់នៅសហរដ្ឋអាមេរិកនិងភាពមិនប្រាកដប្រជានៃពាណិជ្ជកម្មសកល។*


## *វឌ្ឍនភាពសេដ្ឋកិច្ចថ្មីៗ*

កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថា បានថមថយល្បឿនបន្តិចមកត្រឹម ៦.៩ ភាគរយក្នុងឆ្នាំ ២០១៦ធៀបនឹងអត្រា ៧ ភាគរយក្នុងឆ្នាំ ២០១៥ ក្នុងបរិបទនៃការបន្ថយល្បឿនការនាំចេញសម្លៀកបំពាក់ ។ អត្រាកំណើននៃការនាំចេញសម្លៀកបំពាក់បានបន្ថយល្បឿនចុះមកត្រឹម ៨.៤ ភាគរយ (គិតជាតម្លៃ) ធៀបនឹងឆ្នាំ ២០១៥ ដែលមានកំណើនស្មើនឹង ១២.៣ ភាគរយ ។ ការកើនឡើងថ្លៃពលកម្ម ដែលបង្កមួយផ្នែកដោយសារការកើនឡើងថ្លៃចំណាយនៃការរស់នៅ ការឡើងថ្លៃប្រាក់ដុល្លារអាមេរិក ជាមួយនឹងការប្រកួតប្រជែងពីប្រទេសដទៃទៀតដែលមានតំលៃពលកម្មថោក ជាពិសេសប្រទេសភូមា បន្តដាក់សម្ពាធដល់ការនាំចេញសម្លៀកបំពាក់ ។ ស្ថានភាពធាតុអាកាសល្អប្រសើរ បានលើកកម្ពស់ផលិតកម្មកសិកម្មខណៈដែលកំណើនចំនួនភ្ញៀវទេសចរបន្តថយល្បឿន។ ផលិតកម្មស្រូវរដូវវស្សាបានកើនឡើងដល់ ៧.៣ លានតោន ឬបានកើនឡើង ៨.៩ ភាគរយក្នុងឆ្នាំ ២០១៦ ។ ទោះយ៉ាងណាក្តី ថ្លៃទំនិញកសិកម្មចុះថោកធ្វើឲ្យប៉ះពាល់ដល់ការនាំចេញទំនិញកសិកម្ម ។ ដោយសារពុំសូវមានភាពជោគជ័យក្នុងការធ្វើពិពិធកម្មតំបន់ទាក់ទាញភ្ញៀវទេសចរឲ្យលើសពីតំបន់ប្រាសាទអង្គរវត្តនៅឆ្នាំ ២០១៦ កំណើនភ្ញៀវទេសចរអន្តរជាតិបានបន្តថមថយល្បឿនមកត្រឹម ៥ ភាគរយធៀបនឹងឆ្នាំ ២០១៥ ដែលមានអត្រាកំណើនស្មើនឹង ៦.១ ភាគរយ ។

គ្រួសារនៅតាមជនបទបានធ្វើពិពិធកម្មកាន់តែច្រើនឡើងលើរបរចិញ្ចឹមជីវិត ដោយការទាញប្រយោជន៍ពីសេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទ និងការបង្វែរប្រាក់ដើម្បីជួយទ្រទ្រង់ដល់ការកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ។ ការធ្លាក់ចុះថ្លៃកសិផលគួបផ្សំនឹងព្រឹត្តិការណ៍អាកាសធាតុនៅឆ្នាំ ២០១៣ និងឆ្នាំ ២០១៥ ធ្វើឲ្យផសសកសិកម្មធ្លាក់ចុះហើយស្ថិតនៅទ្រឹងក្នុងរយៈពេលប៉ុន្មានឆ្នាំងចុងក្រោយនេះ។ ទោះជាយ៉ាងណាក្តី ចាប់តាំងពីឆ្នាំ ២០១២ មកគ្រួសារនានាបានចាប់ផ្តើមនូវពិពិធកម្មប្រភពប្រាក់ចំណូលរបស់ខ្លួនរួចជាស្រេចហើយ ។ នៅត្រឹមឆ្នាំ ២០១៤ ចំណូលប្រាក់បង្វែរមិនមែនបានមកពីការលក់ពលកម្ម និងប្រាក់ឈ្នួលមិនមែនកសិកម្មមានចំនួនលើស ៥៤ ភាគរយនៃប្រាក់ចំណូលនៅជនបទ ដែលនៅឆ្នាំ ២០០៧ មានកម្រិតតិចជាង ៣១ ភាគរយតែប៉ុណ្ណោះ។ ដូច្នេះមានការរំពឹងថា ភាពក្រីក្របានបន្តធ្លាក់ចុះ ទោះបីជាវិស័យកសិកម្មនៅទ្រឹងក្តី គឺបានជំរុញការកាត់បន្ថយភាពក្រីក្ររហូតដល់ឆ្នាំ ២០១២ ។

ស្ថានភាពពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាមានភាពប្រសើរឡើង ដោយសារប្រេងបន្តមានតម្លៃទាប និងការរឹតត្បិតកំណើននៃការនាំចូល ដោយសារកំសោយនៃតម្រូវការសម្ភារៈសំណង់មូលដ្ឋាន។ ឱនភាពគណនីចរន្ត (មិនរួមបញ្ចូលប្រាក់បង្វែរផ្លូវការ) ត្រូវបានប៉ាន់ប្រមាណថា បានធ្លាក់ចុះមកត្រឹម ៩.៥ ភាគរយនៃផសសនៅឆ្នាំ ២០១៦ ធៀបនឹង ១០.៦ ភាគរយ នៅឆ្នាំ ២០១៥ ហើយបន្តទទួលហិរញ្ញប្បទានចម្បងពីវិនិយោគផ្ទាល់ពីបរទេស ដែលមានចំនួនស្មើនឹង ១០.២ ភាគរយនៃផសស ។ ទុនបម្រុងអន្តរជាតិសរុបកើនឡើងបន្ថែមទៀតដល់ ៦.៤ ប៊ីលានដុល្លារអាមេរិក (ឬស្មើនឹងការនាំចូលរយៈពេល ៥.៤ ខែ) នៅចុងឆ្នាំ ២០១៦ ធៀបនឹង ៥.៦ ប៊ីលានដុល្លារអាមេរិកនៅឆ្នាំ ២០១៥ ។ ជាទូទៅអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនៅតែមានស្ថេរភាពក្នុងអត្រា ៤.០០០ រៀលក្នុងមួយដុល្លារ ។

កំណើនឥណទានបានបន្ថយល្បឿន។ កំណើនរូបិយវត្ថុទូទៅបានកើនឡើងនៅចុងឆ្នាំ២០១៦ ដល់១៧.៩ ភាគរយ ធៀបនឹង ១៤.៧ ភាគរយនៅឆ្នាំ២០១៥ ដោយសារការកើនឡើងនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស។ នៅចុងឆ្នាំ ២០១៦ កំណើនឥណទានក្នុងស្រុកបានថយចុះមកត្រឹម ២៥.៨ ភាគរយធៀប នឹង២៨.៦ ភាគរយនៅឆ្នាំ ២០១៥ ដែលមួយផ្នែកជាលទ្ធផលនៃការដាក់ចេញនូវវិធានការប្រុងប្រយ័ត្នផ្នែកម៉ាក្រូ។ ការបង្កើនទំនុកចិត្ត អាចទាក់ទាញបាននូវប្រាក់បញ្ញើរបស់វិស័យឯកជនដែលបានកើនឡើង ១៩.៣ ភាគរយ នៅចុងឆ្នាំ ២០១៦ ធៀបនឹង ១៦.៦ ភាគរយក្នុងឆ្នាំ ២០១៥ ។

អតិផរណាបន្តកើនឡើងបន្ថែមទៀតបង្ករដោយកំណើននៃការប្រើប្រាស់ ។ អតិផរណាបានកើនឡើងដល់ ៣.៩ ភាគរយ ធៀបនឹង២.៨ ភាគរយនៅចុងឆ្នាំ ២០១៥ ។ ភាពរឹងមាំនៃតម្រូវការក្នុងស្រុកគាំទ្រដោយការប្រើប្រាស់គ្រួសារ ជាមួយនឹងកំណើនប្រាក់បៀវត្ស នៅតែមានជាបន្ត។

ការបង្កើនប្រាក់ខែក្នុងវិស័យសាធារណៈ ធ្វើឲ្យមានឱនភាពសារពើពន្ធបន្តិចបន្តួច ។ នៅឆ្នាំ ២០១៦ ចំណាយសាធារណៈត្រូវបានប៉ាន់ស្មានថា បានកើនដល់ ២១.៤ ភាគរយនៃផលិតផលក្នុងស្រុកសរុប ។ ចំណាយនេះកើនឡើងដោយកំណើនប្រាក់ខែ ដែលកើនឡើងពី ៦.៥ ភាគរយក្នុងឆ្នាំ ២០១៥ ដល់ ៧.៤ ភាគរយ នៃផសស ក្នុងឆ្នាំ ២០១៦ ខណៈដែលចំណាយមូលធនបានធ្លាក់ចុះពី ៧.៨ ភាគរយដល់ ៧.២ ភាគរយក្នុងអំឡុងពេលដូចគ្នា ។ ការប្រមូលប្រាក់ចំណូលនៅតែរឹងមាំ ក្នុងកម្រិតប៉ាន់ប្រមាណស្មើនឹង ១៨.៥ ភាគរយនៃផសស ក្នុងឆ្នាំ២០១៦។ ដូច្នេះ ឱនភាពសារពើពន្ធសរុប (រួមទាំងជំនួយឥតសំណង) បានកើនឡើងដល់ ១.៩ភាគរយនៃផសស នៅឆ្នាំ ២០១៦ ធៀបនឹងតុល្យការសារពើពន្ធក្នុងឆ្នាំ ២០១៥ ។ ចំណាត់ថ្នាក់កង្វល់បំណុលរបស់ប្រទេសកម្ពុជានៅតែមានកម្រិតទាប បើតាមការសិក្សាចុងក្រោយបំផុតរបស់ធនាគារពិភពលោក/មូលនិធិរូបិយវត្ថុអន្តរជាតិស្តីពីការវិភាគនិរន្តភាពបំណុលដែលបានធ្វើនៅឆ្នាំ ២០១៦ ។

## *ទស្សនវិស័យ*

កំណើនសេដ្ឋកិច្ចត្រូវបានព្យាករថានឹងនៅតែស្មើនឹង៦.៩ ភាគរយ នៅឆ្នាំនេះនិងឆ្នាំក្រោយ ប៉ុន្តែនឹងថយចុះបន្តិចដល់ ៦.៧ ភាគរយនៅឆ្នាំ ២០១៩ (តារាងលេខ ២)។ ខណៈដែលមានកំណើនមួយផ្នែក ដោយសារចំណាយរបស់រដ្ឋាភិបាលកើនឡើងនោះ ក៏មានសញ្ញាមួយចំនួននៃការបន្ថយល្បឿនកំពុងកើតមានដែរ ជាពិសេសក្នុងវិស័យសំណង់ និងវិស័យកាត់ដេរ ។ មានការរំពឹងទុកអំពីការកើនឡើងជាសន្សឹមៗនៃវិស័យកសិកម្ម ដោយសារកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់ ខណៈដែលយើងអាចឃើញមានការធ្វើឱ្យប្រសើរឡើងខ្លះៗក្នុងវិស័យទេសចរណ៍ ដែលមួយផ្នែកគាំទ្រដោយការហោះហើរផ្ទាល់ ដែលទើបត្រូវបានបង្កើតឡើងនិងគំនិតផ្តួចផ្តើមថ្មីៗមួយចំនួនដើម្បីជំរុញកំណើនភ្ញៀវទេសចរណ៍ ដូចជា "ការត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលទេសចរចិន"។ ក្នុងរយៈពេលមធ្យម ទស្សនវិស័យកំណើនសេដ្ឋកិច្ចនៅតែមានលក្ខណៈអំណោយផល ដែលទ្រទ្រង់ដោយសមាហរណកម្មក្នុងតំបន់។

សេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទអាចជាកត្តារួមចំណែកមួយយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រនិងវិបុលភាពទូទៅនៅប្រទេសកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។ កម្ពុជាមានលក្ខណៈស្រដៀងគ្នាទៅ នឹងវៀតណាម ដែលពិពិធភាពនៃរបរចិញ្ចឹមជីវិតនៅតំបន់ជនបទ បានរួមចំណែកដល់ការកាត់បន្ថយភាពក្រីក្រនិងវិបុលភាពទូទៅ ខណៈដែលប្រាក់ចំណូលកសិកម្ម មិនមែនជាប្រាក់ឈ្នួលមានចំនួនប្រហែល ៣៦ ភាគរយរួចទៅហើយនៃប្រាក់ចំណូលសម្រាប់ប្រជាជន ៤០ ភាគរយ ដែលមានចំណូលទាបក្នុងឆ្នាំ ២០១៥ ។ ចំណុចនេះមានន័យថាសេដ្ឋកិច្ចមិនមែនកសិកម្មនៅជនបទនិងការបង្វែរប្រាក់អាចជាកត្តាសំខាន់មួយក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជាក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ។

ហានិភ័យចំពោះទស្សនវិស័យនេះ ភាគច្រើនគឺបណ្តាលមកពីកត្តាក្រៅស្រុក ។ កត្តាទាំងនោះរួមមានផលអវិជ្ជមានពីការតម្លើងអត្រាការប្រាក់នៅសហរដ្ឋអាមេរិក ការងើបឡើងវិញយឺតយ៉ាវនៃសេដ្ឋកិច្ចអឺរ៉ុប និងភាពមិនប្រាកដប្រជាចំពោះពាណិជ្ជកម្មពិភពលោក។ ចំណែកកត្តាក្នុងស្រុកវិញគឺអាចបណ្តាលមកពីភាពមិនប្រាកដប្រជាទាក់ទងនឹងការបោះឆ្នោតនៅឆ្នាំ ២០១៨។

## *ហានិភ័យនិងភាពប្រឈម*

ដើម្បីជម្រុញកំណើនតទៅអនាគត ជាការចំបាច់ត្រូវបង្កើនវិនិយោគមូលធនដែលបាននិងកំពុងធ្លាក់ចុះ។ ការលើកកម្ពស់ការគ្រប់គ្រងវិនិយោគសាធារណៈ គឺជាបុរេលក្ខខ័ណ្ឌដើម្បីធានាប្រសិទ្ធភាពចំណាយ ទន្ទឹមនឹងការជម្រុញវិនិយោគក្នុងវិស័យគាំពារកំណើន និងវិស័យគាំទ្រពលរដ្ឋក្រីក្រ ដូចជាហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ធារាសាស្ត្រ អប់រំ និងសុខាភិបាល ។ ជាមួយគ្នានេះក៏ត្រូវកសាងសមត្ថភាពនៅតាមបណ្តាក្រសួងស្ថាប័នសំខាន់ៗ និងនៅតាមក្រសួងស្ថាប័នពាក់ព័ន្ធផងដែរ។

ការលើកកម្ពស់ផលិតភាពការងារគឺជាគន្លឹះក្នុងការប៉ះប៉ូវចំពោះការបង្កើនយ៉ាងឆាប់រហ័សនៃប្រាក់ឈ្នួលក្នុងវិស័យឯកជន។ ក្នុងរយៈពេលខ្លី តម្រូវឲ្យមានការជំរុញការលើកកម្ពស់ជំនាញវិជ្ជាជីវៈ និងជំនាញបច្ចេកទេស និងកាត់បន្ថយថ្លៃថាមពលដើម្បីទាក់ទាញ និងប្រកួតប្រជែងលើការផលិតដែលមានតម្លៃបន្ថែមខ្ពស់ និងការផលិតដែលកាន់តែទំនើប។ វិនិយោគចំពោះមុខលើការកែលម្អលទ្ធផលនៃការសិក្សាបន្ថែមទៀត ជាមួយនឹងការបង្កើនលទ្ធផលសិក្សាកម្រិតមធ្យមសិក្សាគឺជាគន្លឹះសម្រាប់ភាពជោគជ័យនាពេលអនាគត ។ ការណ៍នេះ និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពចំពោះភាពងាយរងគ្រោះកម្រិតខ្ពស់ទល់នឹងវិបត្តិនានាក៏ជាគន្លឹះសំខាន់សម្រាប់លើកស្ទួយចល័តភាពសេដ្ឋកិច្ចសង្គមនៅកម្ពុជាផងដែរ។

**រូបលេខ ១: ការរួមចំណែកចំពោះកំណើនពិតរបស់កម្ពុជា**
(គិតជាភាគរយ)




ប្រភព:វិទ្យាស្ថានជាតិស្ថិតិនិងការប៉ាន់ស្មានរបស់បុគ្គលិកធនាគារពិភពលោក

**រូបលេខ ២: និន្នាការថ្លៃអង្ករនៅកម្ពុជា**
**និងប្រាក់បង្វែរពីក្រៅប្រទេស**




ប្រភព: World Bank Commodity Price Database, WDI

| តារាងលេខ ២: សូចនាករសំខាន់ៗរបស់កម្ពុជា | 2014 | 2015 | 2016 e | 2017 f | 2018 f | 2019 f |
|---|---|---|---|---|---|---|
| **កំណើនផសស ពិត តាមថ្លៃទីផ្សារថេរ** | 7.1 | 7.0 | 6.9 | 6.9 | 6.9 | 6.7 |
| ការប្រើប្រាស់ផ្នែកឯកជន | 4.5 | 5.9 | 6.7 | 2.1 | 3.8 | 3.5 |
| ការប្រើប្រាស់ផ្នែករដ្ឋាភិបាល | 2.4 | 4.4 | 5.7 | 13.2 | 18.5 | 10.8 |
| វិនិយោគមូលធនអចល័តដុល | 9.1 | 10.6 | 10.1 | 9.8 | 11.5 | 12.5 |
| ការនាំចេញ ទំនិញនិងសេវា | 11.3 | 7.2 | 8.6 | 8.1 | 8.3 | 8.3 |
| ការនាំចូល ទំនិញនិងសេវា | 10.1 | 6.5 | 8.6 | 5.8 | 7.9 | 7.9 |
| **កំណើនផសស ពិត គិតតាមកត្តាថ្លៃថេរ** | 6.9 | 6.9 | 6.8 | 6.8 | 6.8 | 6.6 |
| កសិកម្ម | 0.3 | 0.2 | 1.2 | 1.0 | 0.8 | 0.7 |
| ឧស្សាហកម្ម | 9.8 | 11.7 | 10.4 | 9.8 | 8.9 | 8.8 |
| សេវាកម្ម | 8.7 | 7.1 | 6.8 | 7.1 | 8.0 | 7.2 |
| **អតិផរណា (សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់)** | 1.7 | 1.3 | 3.5 | 3.7 | 4.2 | 5.2 |
| **សមតុល្យគណនីចរន្ត (% នៃផសស)** | -11.3 | -12.1 | -10.5 | -10.1 | -9.8 | -9.3 |
| **គណនីហិរញ្ញវត្ថុនិងមូលធន (% នៃផសស)** | 14.6 | 14.2 | 13.6 | 12.0 | 11.0 | 10.8 |
| **វិនិយោគផ្ទាល់ពីបរទេសសុទ្ធ (% នៃផសស)** | 10.0 | 9.1 | 10.2 | 9.4 | 7.7 | 6.5 |
| **តុល្យការសារពើពន្ធ (% នៃផសស)** | -3.8 | -1.9 | -3.0 | -5.1 | -4.8 | -4.5 |
| **បំណុល (% នៃផសស)** | 32.0 | 32.1 | 32.9 | 33.5 | 33.8 | 33.6 |
| **តុល្យការបឋម (% នៃផសស)** | -3.1 | -1.6 | -2.6 | -4.7 | -4.4 | -4.1 |

ប្រភព: Macroeconomics and Fiscal Management Global Practice, and Poverty Global Practice របស់ធនាគារពិភពលោក
សម្គាល់: e= ប៉ាន់ស្មាន f = ព្យាករណ៍